# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០១ សសរ

## សេចក្តីសំរេច
### ស្តីពី
### ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យវាយតំលៃ ការជួសជុលស្តារឡើងវិញ និង ទទួលពហុកីឡាដ្ឋានជាតិអូឡាំពិក

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/ ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដាឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញកិច្ចសន្យាស្តីពីការជួសជុលពហុកីឡាដ្ឋានអូឡាំពិកនិងការវិនិយោគ សាងសង់សំណង់សណ្ឋាគារ មជ្ឈមណ្ឌលពាណិជ្ជកម្ម លើដីទំនេរនៅជុំវិញពហុកីឡាដ្ឋានជាតិអូឡាំពិក ចុះថ្ងៃទី ២៩ ឧសភា ឆ្នាំ ២០០០ រវាងរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងអប់រំ យុវជន និងកីឡា និងក្រុមហ៊ុនយានពាយសំណង់វិស្វកម្ម
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា

## សំរេច

**ប្រការ១ :** បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីពិនិត្យវាយតម្លៃការជួសជុលស្តារឡើងវិញ និង ទទួលពហុកីឡាដ្ឋានជាតិអូឡាំពិកកម្ពុជាដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | ប្រធាន |
| ២-ឯកឧត្តម សេង លឹមនៅ | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម ម៉ម សូផាណា | អនុរដ្ឋលេខាធិការក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៤-ឯកឧត្តម ប៊ូ ជុំសេរី | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៥-លោក ជា អឿង | អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |

| | | |
|---|---|---|
| ៦ -លោក លី សទ្ធិ | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ៧ -លោក លាស់ សាឡាក់ខាន់ | អនុប្រធាននាយកដ្ឋានអប់រំកាយនិងកីឡា | សមាជិក |
| ៨ -លោក ឡាយ បូរិន | អនុប្រធាននាយកដ្ឋានសំភារៈនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ៩ -លោក បៀន ពុងហ៊ូ | អនុប្រធាននាយកដ្ឋានសំភារៈនិងទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១០ -លោក សេង សារិន | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១១ -លោក សុខ លក្ខិណា | នាយករងខុទ្ទកាល័យ សាលាក្រុងភ្នំពេញ | សមាជិក |
| ១២ -លោក យស់ ឆោមណារ៉ាឌី | អនុប្រធានមន្ទីរ ដនសស ក្រុងភ្នំពេញ | សមាជិក |
| ១៣ -លោក ឈៀង វិបុល | ប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៤ -លោក វ៉ៀម ចាន់លី | ប្រធានការិយាល័យ ទ្រព្យសម្បត្តិរដ្ឋ | សមាជិក |
| ១៥ -លោក នួន សំបូរ | អនុប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៦ -លោក ជា ស្រ៊ុន | អនុប្រធានការិ.សំណង់មន្ទីរ ដនសស ក្រុងភ្នំពេញ | សមាជិក |
| ១៧ -លោក ហ៊ូ វ៉ាន់ថន | អនុប្រធានការិយាល័យ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ១៨ -លោក អំ ប៊ុនលី | ប្រធានការិយាល័យរៀបចំ ដនសស ខ័ណ្ឌ ៧មករា | សមាជិក |
| ១៩ -លោក ព្រុំ ដារ៉ា | មន្ត្រីនាយកដ្ឋានសំភារៈ និង ទ្រព្យសម្បត្តិរដ្ឋ | សមាជិក |

**ប្រការ២ :** គណៈកម្មការនេះមានភារកិច្ចត្រួតពិនិត្យ រាល់ការងារជួសជុលឡើងវិញហេដ្ឋារចនាសម្ព័ន្ធពហុកីឡាដ្ឋានជាតិអូឡាំពិក របស់ក្រុមហ៊ុនយានតាយសំណង់វិស្វកម្ម សមស្របទៅនឹងកិច្ចសន្យា ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០០ និងសៀវភៅបន្ទុក ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ ដើម្បីទទួលពហុកីឡាដ្ឋានជាតិអូឡាំពិកមកប្រើប្រាស់ ។

**ប្រការ៣:** គណៈកម្មការនេះមានសិទ្ធិចាត់ចែងមន្ត្រីរាជការក្រោមឱវាទរៀង១ខ្លួន អោយជួយក្នុងការងារ និងមានសិទ្ធិបង្កើតក្រុមការងារមួយចំនួន ។

**ប្រការ៤ :** សមាសភាពគណៈកម្មការនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ សាលាក្រុងភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាម៉ីខ្លួន ដែលមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

<u>ចំលងជូន:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ